« Neang Pin Sondap » R-6

[illegible]

ARCHIVES NATION...
COTE

# រឿងនាងពិនសណ្ដាប់



R-2
D-88
ខ-ខ
165

ថ្លៃ ០៦៛០០

# រឿងនាងពីរដណ្ដប់ ១

B-2
D-88
N-2938

ARCHIVES NATIONALES
COTE 13-28-205 88

កើតឡើងដោយសាលោក

ឡុងប៉េង-ជួន យន់

23-15-33
1952

បានចម្លងយកមកឲ្យខ្ញុំ

បណ្ណាល័យជាតិ
លេខកូដ: 88
2938

ខ្ញុំក៏បានតែងទៅជាពាក្យកាព្យ

ដើម្បីឲ្យស្រួលដល់កុមារកុមារីទើបនឹងរៀនអាន

ហេតុនេះខ្ញុំសូមអភ័យទោសដល់អស់លោកជាបណ្ឌិតកវី

បើអានទៅឃើញថា ពាក្យពុំសូវប្រសើរសូមមេត្តាខន្តីអភ័យទោសដល់ខ្ញុំ

បណ្ណាគារ. គិម-អ៊ី លេខ ៨៨
វិថីអែមេក្រង់ ភ្នំពេញ

គ្រាសទី១

ព. ស. ២៤៩៦ គ. ស. ១៩៥២

# រឿងនាងពីរដណ្តប់

យើងនឹងជំណាលកាលពីព្រេង  បុរសនេះឯងប្រពន្ធប្តី
កាប់ឧសទៅលក់ជាប្រក្រតី  ក្រស៊ើររកស៊ីបរិភោគគ្មាន ៗ
រកព្រឹកស៊ីល្ងាចជាពល់ថ្ងៃ  ខំប្រឹងស៊ើក្សយតាំងពីព្រាណ
យប់ថ្ងៃព្រួយណាស់ដោយស្រែកឃ្លាន  ពុំដែលឲ្យបានស្រួលពេលណា ៗ
ណាមួយភរិយានាងមានផ្ទៃ  ពោះធំពេកក្រៃប្លែកអស្ចារ្យ
ធំប្លែកជាងគេផងនានា  ពុំងារនាងប្រាប់ទៅស្វាមី ៗ
ថានៃ!អ្នកបងប្អូនឈឺពោះ  មាណពក៏ស្ទុះមកឃាត់ខ្ចី
នាងក៏ប្រសូត្របុត្រស្ទួនស្រី  ដប់ពីរឥតបីមានប្រុសមួយ ៗ
មាណពឃើញហើយស្រែកថាអើ!  កម្មអញហើយតើក្បាលរង្វួយ
ដល់ពីរដណ្តប់គ្មានប្រុសមួយ  កង្វចិត្តវែងព្រួយព្រោះខ្លួនក្រ ៗ
មិនដឹងបានអ្វីមកចិញ្ចឹម  ព្រោះគ្មានសង្ឃឹមមុខរបរ
បានព្រឹកខ្វះល្ងាចជួបបរ  ស៊ីតាំងតែដសោះរាំឃ្លាន ៗ
លុះកូននោះធំបេះដើរខ្ចី  តាំងប្រពន្ធប្តីតែរំខាន
ដោយរកបាយឲ្យកូនស៊ីគ្មាន  ពីរប្រាណជំនុំស្រុះចិត្តគ្នា ៗ
លុះព្រឹកដល់ពេលទៅកាប់ឧស  នាំកូនទៅប្រាសក្នុងអដ្វា
ហើយត្រឡប់មកដល់គ្រឹហា  លើកដៃសច្ចាថាគុណព្រះ ៗ
តាំងគុណទេវតារក្សាព្រៃ  ជួយកូនខ្ញុំនៃឲ្យបានឈ្នះ
អស់សត្វផងកុំបំប៉ះ  កុំឲ្យប្រទះនឹងទុក្ខព្រួយ ៗ
សូមឲ្យបានសុខនឹងចំរើន  នាមឈ្មោះក៏កើនជួបគេស្ទួយ

មាត់ថាចិត្តគិតស្ងួបគេជ្រួយ ព្រោះក្បាលរង្វើយនៅក្នុងព្រៃ ។
កាលនោះនាងពៅជាប្អូនគេ ចេះរិះគិតរកផ្លូវវៃ
នាំបងទាំងនោះដើរឃ្លាតខ្លី ស្រីថ្ងៃមកដល់ផ្ទះវិញណា ។
ឯម្ដាយឃើញហើយទ្រូងតឹងផ្អឹស ទង្គឹសខ្សឹកខ្សួលអួលទុក
តែនឹកថាបើទុករក្សា មុខក្ស័យជីវ៉ាទាំងអស់គ្នា ។
លុះកន្លងទៅបានបីថ្ងៃ ឪពុកនាំវៃដើរម្នីម្នា
ចូលក្នុងព្រៃជ្រៅឆ្ងាយមហិមា កូនថាឪទៅឆ្ងាយម្ល៉េះ ។
មាណពថាបើកូនឯងហត់ ឪកូនកំសត់ឈប់ត្រង់នេះ
ចាំឪចូលទៅនឹងរកបេះ ប្រឡេះផ្លែឈើឲ្យកូនញ៉ាំ ។
ហើយឪចូលទៅកាប់ឧសផង នេះម្ដងបូរកូនឯងនៅចាំ
កុំដើរទៅណាខ្លាចសត្វខាំ ទំរាំឪរកកាប់ឧសបាន ។
ប្រាប់ហើយចេញដើរបង្ហួសទៅ ដល់ទីលំនៅជាសុខសាន្ត
ឯកូននៅចាំត្រាំពុំបាន ព្រោះឃ្លានអាហារមុខក្រៀមផ្អេរ ។
តាំងពីព្រលឹមទល់ថ្ងៃត្រង់ ទាំងប្អូនទាំងបងក្រោកដើរស្ទាះ
រកមើលផ្លែឈើក៏គ្មានសោះ ដោយស្រស់ឃ្លានណាស់ទន់អស់ប្រាណ ។
មួយយំថាឪអ្នកបងអើយ យើងពេលនេះហើយក្ស័យមិនខាន
នឹងចង់ទៅផ្ទះក៏ពុំបាន ព្រោះស្មានមិនត្រូវដឹងផ្លូវណា ។
ហើយនាំគ្នាដើរក្បាលរង្វើយ ណាព្រួយខ្លាចសត្វដំរីខ្លា
ណាអស់កម្លាំងទន់កាយា ពោះរមួលផ្សាដើរជ្រុលជ្រប់ ។

នាងពៅថាឱបងតាំងទ្វេ　　យើងគោងរិះរេរកទីឈប់
ប្អូនដើរមិនរួចទ្រមតាំងគ្រប់　　ខំទប់ដើរទៅទៀតពុំបាន ៗ
បងៗ អាណិតប្អូនខ្លាំងពេក　　ហូរហៀរទឹកភ្នែកស្រោចលើប្រាណ
យំព្យូទ្រហឹងកងស្នសាន　　ខ្លះប្រឹងអត់បានគ្រាន់តែពេប ៗ
ខ្លះថ្ងូរហ៊ឺៗ ដូចជាគ្រុន　　ខ្លះភ័យពេកពន់ស្ទុះទៅអែប
ទល់ខ្លួននឹងគេមាត់ក្រៃបែប　　ព្រោះហេតុទឹកខ្លាចសត្វព្រៃខាំ ៗ
ខ្លះថាបងអើយខ្ញុំឃ្លានណាស់　　នាងខ្លះបេះស្លឹកឈើមកញាំ
ខ្លះថាកុំយំខ្លាចសត្វខាំ　　អត់ទ្រាំចាំព្រឹកសូមទៅរក ៗ
លុះយប់នាងតាំងពីរដណ្ដប់　　ដេកលក់ស្ងាត់សព្វដោយលៃលក
ភ្ញាក់ឡើងបងដាស់ប្អូនឲ្យក្រោក　　ទៅរកបេះផ្លែឈើគោក្ដា ៗ
នាងពីរដណ្ដប់ស្ទុះទុកសិន　　យើងនឹងនិទានពីយក្ស
មេម៉ាយអត់ប្ដីនៅកំព្រា　　ឈ្មោះនាងសន្ធមាជាស្ដេចយក្ស ៗ
នាងមានកូនស្រីមួយនៅតូច　　ដើរពុំទាន់រួចរូបសមសក្ដិ
ខំទីទុកនៅប្រាសាទជាក់　　វិលក្សណ៍នាងចេញទៅលេងព្រៃ ៗ
ពោះចុះពោះឡើងតែម្នាក់ឯង　　កណ្ដាលឥតមានគ្នាឡើយនៃ
ទៅឃើញឯក្មេងជាប្រិនក្រៃ　　ខំទីចូលទៅសួរកិច្ចកល់ ៗ
ដឹងថាក្មេងនេះគ្មានម៉ែឪ　　មកនៅក្នុងព្រៃព្រួយអំពល់
ហើយបង្ហាញឲ្យមើលមណ្ឌល　　ដើម្បីនាំចូលទៅរក្សា ៨
រីឯនាងតាំងពីរដណ្ដប់　　ដឹងសព្វគ្រប់ព្រមបរយាគ្រា



ព្រោះយក្សថានាំទៅកោក្ដា    នាងអរម្មីមានាំគ្នាទៅ ៗ
លុះចូលទៅដល់វាំងហើយណា    យក្សប្រាប់បរិវាររំពេចកូវ
ឲ្យរៀបចាយទឹកដោយត្រឹមត្រូវ    ហើយប្រាប់ឲ្យនៅថែរក្សា ៗ
កុំឲ្យដើរទៅទីដទៃ    ក្រែងកើតអប្រិយនាំខូចការ
ព្រោះយក្សបំរុងបរិកោក្ដា    តែធំកាលណាស៊ីហើយនៃ ៗ

វីនាងតាំងពីរដណ្ដប់ណា    គ្មានជឹងចិន្ដាយគិទី
នឹកស្មានថាគេមានមេត្រី    ប្រណីអាណិតព្រោះកំព្រា ៗ
លុះនាងចំរើនវ័យធំឡើង    ឆោមឆើតរូបល្អសមសោភា
មុខមូលក្រឡង់ដូចចន្ទ្រា    ល្អដូច ៗ គ្មានឥតមានខ្ចោះ ៗ
ថ្ងៃមួយខិទីបង់គោត្ដា    ហើយប្រាប់សេនាឲ្យដឹងស្មោះ
ថាស្អែកនាំនាងបងបង្អស់    យកទៅខាងនោះពិឃាដខ្ទី ៗ
ថ្ងៃងពីទេត្ដារក្សាបាន    ដឹងដានថ្ងៃស្អែកនាងខិទី
ពីឃាដនាងបងធ្វើបំណី    ទេវតាឃ្មាតខ្មីប្រែក្រឡា ៗ
ធ្វើជាកណ្ដុរមួយសស្អាត    សង្អាតកាយរូបធំអស្ចារ្យ
ក្រោមកំពែងពាំងនៃយក្សា    ឲ្យនាងធីតាដើរចេញបាន ៗ
លុះព្រឹកខិទីរៀបអាត្មា    ឡើងជិះគុជសារទៅស្មសាន
កណ្ដុរទេវតាចូលកន្ទបាំង    ប្រាប់នាងកល្យាណឲ្យដឹងក្ដី ៗ
ហើយនាំនាងចេញចរយាត្រា    ពីពាំងយក្សាទៅឃ្មាតខ្ទី
រត់កាត់ព្រឹក្សាដោយកិតភ័យ    ទន់ជើងទន់ដៃយំរន្ធូង ៗ
នាងហត់ខ្លាំងពេកស្រែយំថា    ឱគុណមាតាជួយខ្ញុំផង
តែយក្សមកទាន់គ្រានេះមុង    ស្លាប់តាំងប្អូនបងគ្មានសល់ឡើយ ៗ
នាងបង់យំថាឱកម្មខ្លួន    វេកមកជួនពុំមានស្បើយ
តាំងពីកើតមកជាតិនេះហើយ    កម្មអើយសឹងតែមានទុក្ខា ៗ
នាងពៅថាបងកុំយំថ្វី    ខំដើរឃ្មាតខ្ទីប្រញាប់ការណ៍

ក្រែងយក្សមកទាន់ចាប់អាត្មា    ធ្វើជាអាហារពេលនេះនៃ ៗ
ថ្ងៃពីទិទីស្រីសន្ធមា    ទៅលេងព្រៃក្បាលុះដល់ថ្ងៃ
នឹកឃ្លានអាហារវិលវិញខ្ញី    ខិទីរកនាងពីរដណ្ដប់ ៗ
ពុំឃើញក្រែវក្រោធពិកោធក្រៃ    ហៅអស់សេនីយមកសួរសព្វ
ពុំដឹងនាងខឹងរាយទះតប់    ស្មើរទឹងសន្ធប់ហើយប្រើថា ៗ
ឯងនាំគ្នាទៅរកឲ្យធាប់    ប្រញាប់វិលចូលរាជសេមា
សេនីយត្រូហើយបង្គំលា    រត់ចេញម្នាម្នាដោយភិតភ័យ ៗ
ខ្លះរត់ខ្លះដើរហោះហើរព្រាត    ខំប្រឹងខ្វាឃ្មាតត្រុកព្រៃ
ឆ្លាករកមើលដានដើងស្ត្រី    ខំប្រឹងឃ្មាតខ្វីមិនបានគិត ៗ
ដល់ក្បាលទឹងគុម្ពឈើពុំគប់    ស្មើរទឹងសន្ធប់ហើយភ័យភិត
ស្មានតែគេរាយប្រឹងពិទិត្យ    គ្មានមនុស្សនៅជិតរឹតភ័យខ្លាំង ៗ
នឹកខ្លាចត្រឡប់វិលអាវិញ    ទុកម្ចោះពារម្ចេញស្មារតីតាំង
ស្មើរមិនហ៊ានចូលក្នុងរាជវាំង    ហើយតាំងកាត់ចិត្តផ្សងតាមបុណ្យ ៗ
ដល់ហើយទុនកាយថ្វាយបង្គំ    ប្រណម្យសូមទោសម្ចាស់មានបុណ្យ
ខ្ញុំរកពុំឃើញទេព្រះគុណ    ខុសស៊ុនសូមទានទ្រង់មេត្តា ៗ
ឈប់ស្មេះរឿងយក្សមិនស្រដី    ថ្ងៃពីស្ត្រីនោះវិញណា
នាងពីរដណ្ដប់ចរយាត្រា    ដល់ជិតសេមាស្ដេចមួយអង្គ ៗ
ដើបពះប្រទះស្រះមួយនៃ    មានរាំងដើមជ្រៃនៅនោះធង
ទឹកសោភត្រជាក់ថ្លាកន្លង    នាំខាំងអ្នូនបងចុះមុជលេង ៗ

កៈក្រញ្ញាកក្បោកក្បាបសាបគន្ធា ប្រឡែងខ្សៀវខ្សារហែលទន្ទេង
បេះផ្កាព្រលិតឥតរអែង យកមកទុកលេងដោយល្បែងស្រី ៗ
មុជហើយនាំគ្នាឡើងរហ័ស រួចផ្លាស់សំពត់ប្រញាប់វៃ
ខ្វះផ្លាស់រួចមុនឡើងដើមជ្រៃ ខ្វះប្រឹងឃ្វាតខ្វីឡើងតាមគ្នា ៗ
ថ្វែងពីសោដ័យស្រីក្នុងរាំង ដល់ពេលហើយនាងចេញម្នីម្នា



ទៅរកដងទឹកស្រះរងថ្លា ដល់ស្រេចហើយណាចុះទៅខ្ញី ៗ
ឃើញស្រមោលនាងពីរដណ្ដប់ មើលទៅសព្វៗល្អឥតបី
ស្មានថាខ្លួនឯងស្រស់ប្រិមប្រិយ ស្រដីថាពុំគួរគេប្រើ ៗ
ឲ្យមកដងទឹកដូច្នេះណា ឯងល្អអស្ចារ្យគ្មានគេស្មើ
គួរណាស់តែស្ដេចទ្រង់សរសើរ លើកឯងឲ្យធ្វើជាស្នំឯក ៗ
សៅដៃទឹកទៅពេញឈើចិត្ត ព្រោះគិតថាខ្លួនល្អបំឡែក
តាំងបោកក្អមផ្ទូងតែមិនបែក ព្រោះខឹងខ្លាំងពេកបោកត្រូវទឹក ៗ
នាងពិរដណ្ដប់ដងសព្វគ្រប់ នាងទប់មិនបានសើចព្រឹក
សៅដៃងាកមើលឃើញស្មើរក្លូក នាងនឹកថានេះពេញហៅល្អ ៗ
បើដូច្នេះអញទៅទូលក្សត្រថ្ងៃ ប្ហូសថាព្រះទ័យទ្រង់ត្រេកអរ
ឲ្យនាំចូលទៅក្នុងនគរ ភូធរតាំងធ្វើជាស្នំឯក ៗ
លុះចូលទៅដល់ថ្វាយបង្គំ ទូលព្រះបរមមិនរារែក
ថាមានស្រីល្អរូបយ៉ាងឯក ល្អប្លែកផងស្រីផងនានា ៗ
មហាក្សត្រឮហើយទ្រង់ត្រេកអរ ព្រះទ័យស្មោះសហើយសួរថា
នាងឯងបានឃើញនៅឯណា សៅដៃប្រាប់ថានៅមាត់ស្រះ ៗ
ក្សត្រាទ្រង់ឮពាក្យទាសី ខំប្រឹងឃ្មាតខ្មីយ៉ាងរហ័ស
សេនាដើរតាមពីក្រោយប្ហូស ទៅដល់មាត់ស្រះឃើញនាងល្អ ៗ
ដូចពាក្យទាសីថាប្រាកដ សាច់ម៉ដ្ឋមុខមូលសម្បុរស
បង្កើនរាងរៀវដូចកីណ្ណរ នេះពេញហៅល្អគួរបេតនា ៗ

ទ្រង់ត្រាស់ឲ្យហៅចុះមកដី ហើយសួរសេចក្ដីគ្រប់ប្រការ
បានដឹងដំណើរហើយក្សត្រា ហៅចូលសេមាំរពេចខ្មី ៗ
ទ្រង់សព្វព្រះទ័យដោយរូបល្អ ហើយក៏តាំងនាងជាមហេសី
នៅក្នុងប្រាសាទសប្បាយក្រៃ ស្ត្រីឥតមានព្រួយអ្វីឡើយ ៗ
នាងពីដណ្ដប់ឈប់ស្រដី ថ្ងៃនពីទិនីនោះវិញហើយ
បានដឹងដំណឹងពីត្រាណាត្រយ ក្រេវក្រោធឥតស្បើយក្នុងចិន្ដា ៗ
ថានាងបានធ្វើជាមហេសី ស្ដេចគ្រង់ដែនដីធំអស្ចារ្យ
យក្សនឹកថាបើដូច្នេះណា អញទៅមើលវាឲ្យដឹងក្ដី ៗ
ហើយហៅកូនមកផ្ដែផ្ដាំថា នៅមើលសេមាណាកូនស្រី
ម្ដាយទៅនគរគេឆ្ងាយក្រៃ កូនស្រីកុំដើរទៅណាឡើយ ៗ
ហើយផ្ដាំអស់ពួកពលសេនា ចូរប្រយ័ត្នការកុំកន្ដើយ
មើលបុត្រីអញឲ្យល្អហើយ កុំឲ្យវាដើរលេងផ្ដេសផ្ដាស ៗ
ផ្ដាំស្រេចយក្សហោះចេញទៅខ្មី ដល់ដើមព្រះដ្រៃដែលមានស្រះ
ហើយនាងចុះទៅយ៉ាងរហ័ស ក្លែងក្លាយបានច្បាស់រូបយ៉ាងល្អ ៗ
ដល់ពេលរសៀលព្រះសុរិយា អស់ពួកទាសាចេញមកស្រះ
បានឃើញយក្សខ្លួនផ្អើលឈូឆរ រត់រ៉ៃទៅទូលស្ដេចវិញខ្មី ៗ
ថាទូលបង្គំទៅដល់ស្រះ ឃើញស្ត្រីមួយច្បាស់ល្អឥតបី
ហាក់ដូចទេវតាឋានសួគ៌ស្រី ល្អផុតលោកកិយរកប្រៀបគ្មាន ៗ
នាងពីរដណ្ដប់ក៏ល្អដែរ ប៉ុន្ដែនៅចាញ់ដោយស្មេះស្មាន

នាងឃើញក្រោយនេះពេញបំណាន កូនលោកនេះគ្មានដូចនាងឡើយ ។
ទ្រង់បានប្រាប់ហើយត្រេកអរណាស់ មានព្រះតម្រាស់ទៅជាត្រើយ
ថាឲ្យនាំមកកុំយូរឡើយ ត្រាណាត្រើយនាងល្អបែបយ៉ាងណា ។
តាសីឮហើយរត់ប្រញាប់ ខំប្រឹងឲ្យឆាប់មិនរេក
ដល់ហើយឱនកាយថ្វាយវន្ទា ថាព្រះភជាមានឱក្ការ ។
សូមម្ចាស់ស្ត្រីទ្រង់យាងទៅ ខុសត្រូវសូមទានប្រោសមេត្តា
សន្ធមាឮហើយអរអស្ចារ្យ បានដូចប្រាថ្នាដែលនាងប៉ង ។
ចុះដើរទៅតាមពួកតាសី ខិនីធ្វើបុកបែបញែងញ៉ង
លុះដើរទៅដល់យល់ច្បាស់ច្បង នួនល្អងចូលទៅថ្វាយបង្គំ ។
ព្រះអង្គទ្រង់ទតយល់កាលណា ព្រះទ័យស្នេហាគួបយ៉ាងម៉ាំ
ហើយលើកតម្កើងធ្វើជាធំ ថ្នាក់ថ្នមមិនឲ្យទាស់ចិន្តា ។
ជាទៀងរាល់ថ្ងៃនាងសន្ធមា ប្រើទាំងអស់គ្នាតតមេត្តា
នាងពីដណ្ដប់នោះឯងណា ធីតាខំប្រឹងបំរើរ៉ ។
ថ្ងៃមួយនាងធ្វើពុតជាឈឺ ដេកថ្ងូរហ៊ឺៗដោយមាយា
លុះស្ដេចទ្រង់ជ្រាបទៅសួរថា នៃកែវដីវ៉ានាងឈឺអ្វី ។
សន្ធមាឮហើយត្រេកអរណាស់ ឆ្លើយថាខ្ញុំម្ចាស់ឈឺសិរសី
នាងពីរដណ្ដប់ឥតប្រណី ខ្ញុំឈឺស្ទើរក្ស័យគ្មានជួយសោះ ។
ខ្ញុំអង្វរឲ្យជួយប្រចាប់ លោសុះមកឈ្មោចឈ្មើខ្ញុំស្មោះ
ខ្លះបាប់កាប់ដៃខ្លះជាន់ពោះ ខ្លះស៊ុះមកចាប់ក្បាលទង្គិច ។

ខ្លះផាន់ហើយឈ្លីគ្មានមេត្តា ខ្លះគប់សិរសាខ្លះមួលមិច
ផាំពេញទាំងប្រាណខ្ញុំស្ទើរផាច់ ខ្យល់មួយរំពេចព្រះគុណអើយ ។
មហាក្សត្រដោយត្រូវស្នេហ៍នាងយក្សព្រះទ័យស្មោះស្ម័គ្រឥតមានស្បើយ
សព្វព្រះទ័យណាស់ប៉ូលកៀកកើយ ថាឱនាងអើយកុំសោកថ្វី ។
បងមិនទុកទេមេអាបលក្សណ៍ ចិត្តវាគាក្រក់គ្មានប្រណី
ប្ដេះយកវាទៅចោលក្នុងព្រៃ កុំទុកវាថ្វីស្រីមោហោ ។
ថាហើយស្ដេចយាងចេញប្រញាប់ ប្រើសេនាចាប់នាំចេញចរ
យកទៅប្រាសចោលក្រៅនគរ មេយក្សត្រកអរស្រុះដើរចេញ ។



មកដល់ឃើញហើយប្រាប់ទៅថា នែពួកសេនាឯងស្ដាប់អញ
យកវាទៅហើយខ្វៀលភ្នែកចេញ ទាំងអស់នេះមិញហើយដាក់ឆាប់ ។
ទៅក្នុងអណ្ដូងមួយខាងនោះ ឲ្យវានៅរស់កុំឲ្យស្លាប់

កាលនាងសន្ធមាចេញបង្គាប់ ស្តេចឥតបានប្រាប់កិច្ចការណ៍សោះៗ
ថ្ងៃពីនាងទាំងពីរដណ្តប់ ស្ទើរទឹងសន្ទប់គង់ពេលនោះ
ព្រោះគេភ្លៀលភ្នែកនាងទាំងរស់ ឈឺនោះរ៉ាហួសវិស័យថា ៗ
ឱកម្មនាងទាំងពីរដណ្តប់ នាងមានគតិគ្រប់ទាំងអស់គ្នា
នឹកថាបាបអ្វីជាតិនេះណា វេទនាកើតមកមិនដូចគេ ៗ
ណាឈឺគង់ភ្នែកពេកកន្ទួង ណាឃ្លានបាយផងគ្មានទំនេរ
វេទនាពេលនេះលំបាកទ្វេរ នឹងរេមិនផុតរត់មិនបាន ៗ
ប្រសិនបើភ្នែកជាទៅព៉ គ្រាន់នឹងប្រវ៉ារត់ចេញឋាន
ឲ្យផុតពីដៃស្រីសាមាន្យ បើខ្វាក់គ្រប់ប្រាណរត់ម្តេចទៅ ៗ
នាងអង្គុយយំទល់មុខគ្នា រាល់ពេលវេលាទ្រូងផ្សាក្តៅ
ដោយឈឺខ្លាំងពេកមុខជាំខ្មៅ ទុក្ខព្រួយក្តៅស្ទើរទឹងក្ស័យ ៗ
ថ្ងៃពីចិណីស្រីសន្ធមា ផ្តាំពួកសេនាផងទីទៃ
ថាបើរ៉ាកើតកូនមកខ្មី ចូរពៃលកុំឲ្យបាយរ៉ាស៊ី ៗ
នាងយក្សផ្តាំនេះដោយបំណង ចិត្តប៉ងសម្លាប់កូនពេញទី
តែអញមិនឲ្យបាយនាងស៊ី មុខតែនារីស៊ីកូនខ្ចី ៗ
លុះកន្ទង់ទៅគ្រប់ខែដប់ នាងពីរដណ្តប់នោះឯងនៃ
ឈឺពោះប្រសូតិបុត្រមកខ្មី ស្រ្តីឃ្លានណាស់គ្មានអ្វីស៊ី ៗ
កាលដើមឲ្យម្នាក់មួយពំនូត លុះនាងប្រសូត្រឈប់ពេញទី
ហេតុនោះនាងឃ្លានគ្មានអ្វីស៊ី នារីហែកកូនចែកគ្នាញាំ ៗ

កូនទាំងដប់មួយស៊ីទាំងរស់ ស៊ីគ្មានសល់សោះហេតុតែកម្ម
បំណែកនាងពៅនាងចេះទ្រាំ នាងខំទុកសាច់នោះទាំងរស់ ។
ដែលបងចែកឲ្យទាំងប៉ុន្មាន កល្យាណនាងគ្មានបរិភោគសោះ
ពេលនាងប្រសូតបុត្រមកនោះ សាច់សល់ទាំងរស់ចែកបងវិញ ។
បង ៗ សង្ស័យពេកអស្ចារ្យ ហើយនាងសួរថាពៅសំឡាញ់
សាច់កូនប្អូនឯងប្រសូតចេញ ស្អុយដូច្នេះមិញតើយ៉ាងណា ។
នាងពៅថាកូនខ្ញុំកើតមក ឆោមស្រស់ពន្លកក្ស័យជីវា
ទើបបានសាច់ស្អុយធុំខា ៗ អស្ចារ្យគឺកម្មមកពីព្រេង ។
នាង ពៅបាននៅសល់ក្មេកខ្មាង មិនសូវគេងតាំងទឹងតាត់តែង
គ្រាន់ថែរក្សាកូននោះឯង មិនសូវបំបែងកូនទ្រូងផង ។
សន្មាតថាកូនទាំងរស់ ស៊ីគ្មានសល់សេសមួយជាម្តង
នាងយក្សត្រេកអរពេកកន្ទង បានដូចបំណងនាងបងហើយ ។
ទើបនាងស្រែកហៅគិលៀនថា ចូរហាងយាត្រាកុំកន្តើយ
កូនវាស៊ីអស់គ្មានសល់ឡើយ ហាងអើយយកបាយឲ្យវានៃ ។
តែកុំយកឲ្យវាច្រើនៈពេក បំពោះហាងចែកឲ្យដល់ដៃ
ម្នាក់មួយពំនូតជាពល់ថ្ងៃ កុំឲ្យតែក្ស័យទៅបានលើយ ។
គិតលោឲ្យច្រើនអញដឹងច្បាស់ ហាងឯងខានតាស់ពេលនេះហើយ
សម្លាប់គ្មានទុកជីវិតឡើយ ហាងដឹងអញហើយចិត្តដូចយក្ស ។
តាសព្ទហើយដើរទៅខ្ចី ឲ្យជាប្រក្រតីមិនហ៊ានអាក់

តែមួយពុំនឹកគន់មួយនាក់ នាងបែកឲ្យផាក់ផាល់ថ្ងៃ ៗ
ថ្ងៃមួយនាងទៅប្រាប់បងៗ ថាកូនខ្លួនល្អន់រស់ទេនៃ
បងៗក្តុះហើយអរពេកក្រៃ ជួយលៃឲ្យនាងបាយបានឆ្អែត ៗ
ព្រោះប្អូនពៅនាងមានកូនខ្ចី បងក៏ប្រណីទៅតាមហេតុ
ឲ្យមានទឹកដោះកូនបៅឆ្អែត ហើយជួយសង្រ្កិតថែតទៅ ៗ
បងៗនឹងនាងពៅផងនៃ លកលៃឲ្យឈ្មោះកូននោះហៅ
ថារិទ្ធិសែនយ៉ាងត្រឹមត្រូវ នាងពៅស្រឡាញ់ស្ទើរដីរ៉ា ៗ
លុះកូននោះធំជំនិតហើយ មិននៅកន្តើយបរយាត្រា
ចេញមកខាងក្រៅតែឯកា កុមាររំកមើលនាយគាយ ៗ
យល់ស្ងាត់ទើបទើតចេញដើរទៅ ឃើញគេផងនៅលេងប្រញាយ
រិទ្ធិសែនចូលទៅដោយរីករាយ ខ្វល់ខ្វាយបបួលគ្នាលេងស្គាល់ ៗ
គេឯងទាំងទៀតឆ្លើយថាអើ បើដូច្នោះតើយើងក៏យល់
ព្រមតាមដាក់អ្វីក៏មិនទាល់ ឲ្យស្គាល់យើងផ្ទាប់ឈ្មោះប្រាក់រយ ៗ
រិទ្ធិសែនក្តុះហើយឆ្លើយឡើងថា ខ្ញុំខ្ញុំនេះណាគ្មានប្រាក់ឲ្យ
ប្រសិនខ្ញុំចាញ់ចាំថ្ងៃក្រោយ បើខ្ញុំមិនឲ្យធ្វើតាមការ ៗ
តែបើខ្ញុំឈ្នះខ្ញុំសូមបាយ តែមួយសំពាយសុំមេត្តា
តើបងព្រមគ្នាលប៉ុយ៉ាងណា គេផងនោះឆ្លើយថាអញសុខចិត្ត ៗ
បើឯងមិនសងអញៗវាយ បាយមួយសំពាយអញមិនគិត
ខ្មោចអាប៉ុណ្ណឹងអញគ្មានគិត គ្មានភ័យគន់ចិត្តប៉ុនកូនដៃ ៗ

និយាយគ្នាស្រេចដាំអង្គញ ចាប់លេងគ្មានធុញកណ្ដាលថ្ងៃ
លេងចាញ់រទ្ធិសែនតែពល់ដៃ ទឹកខឹងចង់ក៏យះឃើញគ្នាតូច ៗ
រទ្ធិសែនមិនស្ដីវីតែលេង ពួកក្មេងនោះឯងមាត់ប្រួច
ចំប្រឹងដម្រង់ក្នៃកម្លាំងតូច សម្រួចបោះទៅរុះសទទេ ៗ
អាមួយលេងចាញ់មួយចូលទៀត រទ្ធិសែនចំភ្លៀតគ្មានចំនេរ
លេងឈ្នះបានបាយច្រើនយ៉ាងទ្វ រិះរេយកទៅជូនមាតា ៗ
កុមារមកលេងជារាល់ថ្ងៃ ក្នុងរូងនោះនៃបានសុខា
ដោយបុណ្យរទ្ធិសែននោះឯងណា ចិញ្ចឹមមាតាដោយសារល្បែង ៗ
លែងអត់លែងឃ្លានបានគ្រប់គ្រាន់ ថ្ងៃមួយបានមាន់បីទន្ទេង
ដើរចូលទៅក្នុងរូងនោះឯង ពួកក្មេងក៏ឲ្យដោយក៏ចាញ់ ៗ
ថ្ងៃមួយកុមារបើដើរមក សួររកថាវ៉ុយអាសំឡាញ់
នរណាមានមាន់ជល់នឹងអញ ឈ្នះចាញ់អញចង់ជល់ភ្នាល់គ្នា ៗ
អាមួយឆ្លើយឡើងថាអញមាន មាន់មួយចំណានកាត់បាក់
ជល់មិនដែលចាញ់មាន់អ្នកណា បើជល់ឯងថាដាក់ប៉ុន្មាន ៗ
ចំណែកខាន់ទៅកុំបាច់គិត អញពិតប្រាក់មាសមិនចង់បាន
ចង់យកតែបាយបួនដប់ចាន គ្រាន់បានយកទៅស៊ីមួយឆ្អែត ៗ
ក្មេងនោះព្រុហើយត្រេកអរណាស់ រត់យ៉ាងរហ័សចាប់មាន់ក្ងួត
បានហើយរត់វិញបីមាន់ផ្ដែត ចូលក្ងួតដាក់មាន់ឲ្យជល់ភ្លាម ៗ
ជល់មួយស្ទុះមាន់ក្មេងចាញ់ ក្មេងនោះទឹកខ្នាញ់យំរហាម

ក្មេងខ្លះរាំវិលពេបមាត់តាម ខ្លះថាអាញ៉ាមអាងធ្លាប់ឈ្នះ ៗ
អានោះខឹងណាស់មិនចេញស្តី ខំរត់ឃ្លាតខ្លីទៅដល់ផ្ទះ
ឃើញបាយក្នុងឆ្នាំងនៅច្រើនណាស់ លើកជះក្នុងកញ្ជើទាំងអស់ ៗ
យកមកឫទ្ធិសែនទទួលភ្លាម មិនទាន់ទំពាមដើរទៅស្មោះ
ដល់មាត់អណ្តូងក៏ដើបុះ ជូនម្តាយទាំងអស់ចែកគ្នាស៊ី ៗ
ឫទ្ធិសែនចេញមកលេងកាលថ្ងៃ សប្បាយពេកក្រៃហាក់រីករី
ក្មេងកាន់តែច្រើនព្រួតពេញទី ព្រួដល់នារីស្រីសន្ធមា ៗ
នាងអើតមកមើលប្រឹងពិនិត្យ ឃើញក្មេងមួយពិតខុសធម្មតា
រូបពង់ក៏ស្អាតគួរចេតនា ធីតាសួរអស់ពួកទាសី ៗ
គ្មាននរណាស្គាល់កូននោះសោះ ដោយស្រស់ប្រិមស់ពួកសេនីយ
ចូរឯងទៅតាមក្មេងនោះខ្លី មើលឲ្យដឹងក្តីកូននរណា ៗ
សេនីយព្រហើយរត់លឿនរឹង គ្រឹងក្ទឹងទៅជិតទាន់កុមារ
ហើយឈប់លបមើលឲ្យដឹងការ ឃើញថាកុមារនោះឯងនៃ ៗ
ចុះក្នុងអណ្តូងដែលគេដាក់ នាងពីរដណ្តប់ដាក់ឥតសង្ស័យ
ហើយវិលមកវិញដោយឃ្លាតខ្លី ចូលទូលក្សត្រីស្រីសន្ធមា ៗ
នាងយក្សព្រហើយត្រេកអរព្រួច គិតគួបក្នុងចិត្តប្រម៉ងថា
អញព្យាបាទពៅពេលនេះណា លុះត្រាក្សីណក្ស័យជីវិតបង់ ៗ
យប់នោះសន្ធមាផ្ទុំពុំលក់ ស្មារតីវិកព្រួយកន្ទួង
ទៀបភ្លឺទើបនឹកឧបាយផង ឃើញដូចបំណងដែលប្រាថ្នា ៗ

ព្រឹកឡើងតើនចាកពីព្រហាម ចេញភ្លាមមកក្រៅហៅសេនា
ថារើយសេនីយមកអាយណ៎ ដ្បិតអញមានការត្រូវប្រញាប់ ៗ
សេនាមកដល់យក្សប្រើថា ទៅហៅកុមារឲ្យយ៉ាងឆាប់
ដែលនៅក្នុងអណ្ដូងនោះស្រាប់ ចូរទៅប្រញាប់កុំបង្អង់ ៗ
អាមាត្យរត់ទៅយ៉ាងឃ្មាតខ្មី ភ្នែកគន់រំពៃក្នុងអណ្ដូង
ឃើញឫទ្ធិសែនហើយហៅជាមួង មិនហ៊ានការង់វិលវិញខ្មី ៗ
ដល់ហើយឱនកាយថ្វាយបង្គំ អង្គុយសម្ងំមិនចេញស្ដី
ព្រោះខ្លាចអំណាចអង្គក្សត្រី គេជាមហេសីព្រះប្ញះប្ញង ៗ
ថ្ងៃតីទិនស្រីសន្ធមា ឃើញអង្គកុមារអេរកទ្ទង
ព្រោះនឹកថាបានដូចបំណង ហើយនាងសាសង់ស្ដីទៅថា ៗ
ខ្ញុំឃើញអ្នកឯងវែងប្រណី ក្នុងពេលនេះនៃខ្ញុំមានការ
ចង់ប្រើឲ្យអ្នកចរយាត្រា នាំសារមួយទៅស្រុកនោះឆ្ងាយ ៗ
បើអ្នកទៅហើយបានសម្រេច វិលមួយរំពេចដោយសប្បាយ
អ្នកនឹងមានលាភធំដល់កាយ ខ្ញុំឲ្យមិនស្ដាយដោយប្រណី ៗ
ឫទ្ធិសែនសុខចិត្តទទួលទៅ ដោយនៅកុមារក្មេងសេចក្ដី
មិនហ៊ានប្រកែកខ្លាចក្សត្រី កីតភ័យមិនហ៊ានតាំងនើបផង ៗ
ខិនីត្ថហើយត្រេកអរណាស់ ថាច្បាស់ជាស្លាប់គ្រានេះម្ដង
ហើយប្រើអស់ពួកសេនីយផង ថាហង់ទៅយកគ្រឿងប្រដាប់ ៗ
ហង់យកតាំងសុរងកឯក ពស្ត្រា យ៉ាងល្អមកឆាប់ៗ

គិលៀនគ្រូហើយស្ទុះប្រញាប់ ទៅចាប់យកមកថ្វាក្សត្រី ៗ
គ្រឿងប្រដាប់នេះសម្រាប់ស្ដេច យ៉ាងល្អបំណាច់ផុតផែនដី
នាងយក្សឲ្យមកកុមារខ្ចី ក្សត្រីប្រគល់សេះមួយទៀត ៗ
សេះនេះក៏សេះសម្រាប់ស្ដេច ហើយនាងវិលគេចខំធ្លាក់ធ្មៀត
សរសេរសំបុត្ររួចហើយសៀត ក្នុងស្រោមបិទជិតយកទៅខ្ចី ៗ
ចងនឹងកសេះរួចស្រេចល្អ កុមារចេញចរសំដៅព្រៃ
តែឯកអង្គាព្រួយពេកក្រៃ ប្រុសថ្ងៃនឹកដល់ព្រះមាតា ៗ
ជិះសេះលេចវាលចូលក្នុងព្រៃ សន្ធឹកសន្ធៃក្នុងកាយា
ហៀរហូរទឹកភ្នែកជោគកាយា ហើយអ្នកថ្ងូញថាឱ! អ្នកម្ដាយ ៗ
ម្ដេះសមអ្នកចាំមើលផ្លូវកូន ដល់ពេលបាត់សូន្យកូនមកឆ្ងាយ
ស្មើនេះកូនធ្លាប់តែបានបាយ យកជូនអ្នកម្ដាយរាល់វេលា ៗ
ថ្ងៃនេះកូនចេញមកផុតហើយ ឱ!អ្នកម្ដាយអើយសបវេទនា
សព្វថ្ងៃបានកូនជូនអាហារ ក្នុងពេលនេះណាសមអ្នកអត់ ៗ
ចាំអាហារដែលគេឲ្យនោះ បំពោះមិនគ្រប់ជាប្រុ.កដ
កើតមកជាតិនេះពេញកំសត់ ថែមគេពង្រាត់ឯងមកទៀត ៗ
ឱ!អ្នកម្ដាយអើយកុំតូចចិត្ត ខ្លួនខ្ញុំនេះឥតបើចង់ឃ្លាត
ដោយខ្ញុំខ្លាចអង្គព្រះមហាក្សត្រ ទើបបានខ្ញុំកាត់ចិត្តចេញមក ៗ
តែខ្ញុំទៅមិនយូរប៉ុន្មាន ប្រញាប់វិលឋានមិននែនក
តែបានដល់ហើយកូនវិលមក រិះរកចំណីចិញ្ចឹមអ្នក ៗ

រិទ្ធិសែនជិះសេះតាំងពីព្រឹក　ផាយលឿនពន្លឹកញើសស្រោក
ខំប្រឹងលុះដល់ថ្ងៃត្រង់ជាក់　ទើបឈប់សម្រាក់ក្រោមដើមជ្រៃ ៗ
កុមារអស់កម្លាំងខ្លាំងពេក　ទើបអ្នកចូលដេកទីនោះនៃ
ឃ្លានបាយដោយអត់លុះទាល់ថ្ងៃ　បាក់ពោះសន្លៃដេកលក់ទៅ ៗ
កាលនោះមានឥសីមួយអង្គ　លោកត្រាចមកត្រង់ទីនោះគួរ
ឃើញកុមារដេកទ្រង់ចូលទៅ　ហើយមានសេះនៅជិតនោះផង ៗ
សេះនោះមានផ្ដាក់ចងត្រង់ក　ឥសីចូលរំដោះជម្រង់
ចាប់ផ្ដាក់មកមើលឃើញក្រឡង់　គឺអង្គរិទ្ធិស្រីសន្ធា ៗ
ផ្ញើទៅឲ្យនាងជាបុត្រី　ឈ្មោះនាងកង្រៃនោះឯងណា
សេចក្ដីសុំបុត្រាជាក់ថា　បើឃើញមនុស្សណាត្រូវសម្លាប់ ៗ
បើរាដល់យប់សម្លាប់យប់　កុំបង្អង់ឈប់តោងកូនស្លាប់
បើចូលដល់ថ្ងៃស្រស់បំណាច់　សម្លាប់ទាំងថ្ងៃកុំបង្អង់ ៗ
ឥស្សីទតយល់ស៊ីខ្លាចចិត្ត　ព្រះទេអាណិតស្រស់ឆោមយង់
មើលមុខស្អាតបាទពុំគួរល្ងង់　ទំនងមិនចេះអក្សរសាស្ត្រ ៗ
បានជាយកមកគ្មានដឹងស្លាប់　មុខតែយក្សកាប់ចោលជាក់ច្បាស់
បើចេះគួរអញប្រែក្រឡះ　ជាក់ថាបើព្រះកុមារទៅ ៗ
ដល់ហើយប្អូនកូនទទួលស្នោះ　យកផ្ញើប្ដីបុះណាស្រីពៅ
រៀបម្ហូបចំណីឲ្យត្រឹមត្រូវ　ផ្ដាប់ផ្គុនគេទៅណាកូនស្រី ៗ
បើព្រះកុមារយាងដល់យប់　ក៏ត្រូវគោរពយកផ្ញើប្ដី

បើព្រះកុមារដល់ពេលថ្ងៃ　គិតតែពីប្ដីកុំបង្អង់ ។
ឥសីសរសេរប្រែរូបហើយ　បិទទ្រោមកន្ដើយមិនករុង
បងនឹងក៏សេះដូចដើមហោង　ហើយវិលតម្រង់ទៅសាលា ។
ថ្ងៃងរិទ្ធិសែនដេកស្កប់ស្កល់　លុះដល់សៀលព្រះសូរិយា
គ្រាកឡើងជិះសេះចេញមីមា　ផាយលឿនអស្ចារ្យប្រញាប់ក្រៃ ។
ព្រោះនឹកតែម្ដាយអត់អាហារ　តែយូរកាលណា ខ្វចក្រែងខ្វ័យ
ហេតុនោះខំស្រូតកាត់ព្រឹកព្រៃ　លុះដល់បូរីស្រីយក្សា ។
ជិះសេះតម្រង់ទៅរកពំង្គ　ពួកយក្សឈប្រចាំងមើលកុមារ
ដោយឃើញរូបល្អចង់ស្នេហា　ឈរក្លែបកាយាស្មារតីកាំង ។
រិទ្ធិសែនឈប់ស្ទុះមិនបរវា　ថ្ងៃងពីជីតានៅក្នុងពំង្គ
ព្រួយចិត្តឥប្រុកព្រះក័ក្រស្ទាំង　សេនាបង្ខាំងមិនឲ្យដើរ ។
ព្រោះនាងសន្ធិមារបានផ្ដាំផ្ដាប់　កុំឲ្យបរត្រាចតាមអំពើ
ចិត្តកេ្តងដែលចង់តែចេញដើរ　រាំមិនប្រសើរកេរ្តិ៍ឈ្មោះឡើយ ។
រាល់ថ្ងៃនាងលេងតែក្នុងពំង្គ　ក៏លៀនប្រួងប្រាំងមិនកន្ដើយ
ជូនទៅសួនច្បារគ្រាន់លំហើយ　បានស្បើយមិនសូវអប្រុកពេក ។
ថ្ងៃមួយរិទ្ធិសែនចូលដល់ពំង្គ　សេនាយក្សខាំងនៅពវែក
រិទ្ធិសែនខឹងណាស់ប្រឹងដៃដក　សម្រែកព្រុដល់ក្នុងប្រាសាទ ។
រីនាងកង្រិសង្ស័យណាស់　ចេញមកឃើញច្បាស់រូបយ៉ាងស្អាត
មិនដឹងហេតុអ្វីខំសន្ធាត　មកហៅអាមាត្យទៅសួរការ ។



រិទ្ធិសែនឃើញរូបនាងកង្រី ព្រះភក្រ្តប្រិមប្រិយ៍ដូចទេវតា
ស្ទើបាត់ស្មារតីដោយស្នេហា ឈរក្ដូចកាយាស្មារតីភាំង ៗ
រួចចុះពីលើខ្នងសេះមក លៃលកស្រាយផ្ដាក់មកប្រដាំង
ហើយលើកដៃក្គុំទាំងសង្ខាង គោរប់ព្រះនាងពេលនោះនៃ ៗ
យកផ្កាកសារៈមកបង្ហាញនាង ភីលៀងទៅយកពានមាសខ្ចី

មកទ្រព្យសារៈថ្វាយក្សត្រិ ឯនាងកន្រីចូលប្រាសាទ ។
រិទ្ធិសែនក៏ចូលតាមនាងទៅ ដោមទៅរៀបកន្ទែងយ៉ាងស្អាត
ហើយអង្គុយទល់មុខគ្នាថ្វាត នាងកន្រីចាត់ឲ្យអានសារៈ ។
អស់ពួកនាម៉ឺនអង្គុយត្រៀប ដំរៀបគ្នាប្រុងចាំស្តាប់ការ
លុះគេស្រូតចប់សេចក្តីសារ ដឹងការត្រេកអរពេកកន្ទង ។
រិទ្ធិសែនហើយនឹងនាងកន្រី ចាប់ចិត្តមេត្រីពេញស្នែស្នង
ប៉ះតែលបមើលគ្នាម្តងៗ ដោយចិត្តបំណងចង់ប្រដិព័ទ្ធ ។
លុះសារៈស្រូតចប់នាងកន្រី ត្រេកអរពេកក្រៃស្មើនឹងលោក
ទៅថ្វាយបង្គំស្តេចកំសត់ បិទមាត់ញញឹមមើលមុខគ្នា ។
ពួកពលសេនានឹងស្រីស្នំ មកថ្វាយបង្គំអង្គក្សត្រា
ដោយបានម្ចាស់ថ្មីត្រង់សោមា ត្រេកអរគ្រប់គ្នាមិនមានទាស់ ។
ហើយរៀបអភិសេកនាងកន្រី នឹងរិទ្ធិសែនទ្វីសោយរាជស្មោះ
ពួកពលសេនាមកចាំងអស់ ចំពោះស៊ីលៀងគ្រប់ ៣ ថ្ងៃ ។
រិទ្ធិសែនឡើងពេញទីជាស្តេច យ៉ាងពិសេសម្រេចក្នុងរាំងជ័យ
រីករាយសប្បាយក្នុងព្រះទ័យ រកអ្វីមកប្រៀបក៏ពុំបាន ។
លុះថ្ងៃរសៀលនាងកន្រី នាំព្រះស្វាមីទៅកំសាន្ត
ឯក្នុងសួនច្បារចាំងពីប្រាណ កល្យាណចង្អុលប្រាប់កន្ទែង ។
ដែលមានស្រះស្រង់នឹងសាលា ហើយមានបុប្ផាល្អយ៉ាងខែង
នៅក្នុងសួននោះផ្កាខ្វាត់ខ្វែង យាងលេងពីរប្រាណកំសាន្តកាយ ។

លុះយានមកដល់ឃុំមួយតូច ព្រះនាងនឹកព្រួយបាត់សប្បាយ
ឈរក្លេចស្មារតីមិនអភិប្រាយ ឆោមឆាយកែណាសញ្ជ័រយោគា ។
រិទ្ធិសែននឹកឆ្ងល់សួរទៅខ្មី ជាឧបរណៃដូងជីវ៉ា
ហេតុអ្វីបានជាក្លេចកាយា សូមកែវមេត្តាប្រាប់បងផង ។
នាងឮប្តីសួរទ្រង់បង្អៀត ហើយឆ្លៀតឆ្លើយថាឱព្រះបង
ប្អូនភ័យខ្លាំងណាស់គ្រានេះម្តង សូមបងកុំចង់ដឹងធ្វើអ្វី ។
ព្រោះកន្លែងនេះមាតាផ្តាំ ឲ្យប្អូនថែទាំកុំស្រដី
កុំឲ្យអ្នកផងគេដឹងក្តី តែដឹងប្អូនស្រីនឹងមាតា ។
មុខតែព្រាត់គ្នាជាប្រាកដ ប្តីមួយស្លាប់បាត់ជន្មជីវ៉ា
មិនបានសុខស្រួលដូចធម្មតា ខ្ញុំខ្លាចសង្ខារក្ស័យចោលអ្នក ។
រិទ្ធិសែនឮហើយរឹតសង្ស័យ មិនដឹងមានអ្វីបានជាលាក់
កុំពុងស្រឡាញ់គ្នាឥតអាក់ នេះជាក់មានការមិនគប្បី ។
នាងឃើញស្វាមីឈរសំកុក បែបទ្រង់កើតទុក្ខនាងនាថភ័យ
ហើយដកកូនសោចូលទៅវៃ ក្សត្រីបំរុងនឹងបើកទ្វារ ។
ប៉ុន្តែជើងដៃញ័រតត្រត់ កូនសោរបូតពីហត្ថា
រិទ្ធិសែនឃើញហើយមានមេត្តា ទើបថាប្អូនកំបើកធ្វើអ្វី ។
គ្រាន់តែប្រាប់បងឲ្យដឹងការណ៍ គឺជាកន្លងនោះមានរបស់អ្វី
ដោយសារកាលមាតាប្អូនស្រី ប្រាប់ក្តីសម្ងាត់បងមិននៅ ។
ប្រសិនបើបងនៅនោះដែរ មាតាមាសស្នែគង់ប្រាប់ផ្លូវ

ឲ្យបងបានដឹងដូចប្អូនពៅ    ហេតុនេះឆោមឆ្ងៅកុំលាក់ថ្វី ៗ
ទើបនាងរិតចូលទៅយ៉ាងជិត    ខ្សឹបៗទាំងគិតប្រាប់ស្វាមី
ថានៅក្នុងឃ្លាំងមានតុះនៃ    ដម្កល់ពានថ្មីធ្វើពីប្រាក់ ៖
ហើយក្រឡៃមាសយ៉ាងស្អាតល្អ    ដាក់ទ្រដបថ្នាំប្រាកដ្ឋដាក់
ហើយមានក្អែកមនុស្សដប់ពីនាក់    គឺដាក់ជិតៈនោះមកយូរក្រៃ ៗ
ថ្នាំនោះបើមាននរណាម្នាក់    គ្រាប់ក្អែកមកខ្វាក់យូរខែរថ្ងៃ
រើសទៅដាក់វិញកុំឲ្យក័ប    យកថ្នាំលាប់ខ្ទើដូចដើម ៗ
ហើយមានដំបងបញ្ចុះមន្ត    អាគុមន៍គ្រប់គ្រាន់ល្អសម្បើម
របស់មាតាខ្ញុំពីដើម    ត្រូវកែយ៉ាងធ្ងើមក្នុងវផ្កា ៗ
គេដាក់នៅបំកណ្ដាលតុះ    ឃាំងទុកកុំឲ្យថ្នាំនោះណា
រត់ចូលក្នុងក្អែកខ្ទបអាសា    យកមកប្រើការពុំបានឡើយ ៗ
រិទ្ធិសែនបានស្ដាប់សព្វសេចក្ដី    ជ្រាបក្នុងព្រះទៃអង្គគ្រាណាត្រើយ
ច្បាស់ជាព្រះនេត្រមាតាហើយ    ទប់ពុំបានឡើយសោយសោក្កា ៗ
រីនាងកង្រីក័យកន្ទង    ស្ទូរថាព្រះបង់សូមមេត្តា
ហេតុអ្វីបានជាសោយសោក្កា    សូមព្រះភស្ដាទ្រង់ប្រណី ៗ
រឿងនេះខុះមកពីខ្លួនខ្ញុំ    បង្គំទូលគ្រប់សព្វសេចក្ដី
របស់ក្នុងឃ្លាំងនេះឯងនៃ    ទើបព្រះបក្រីទ្រង់សោក្កា ៗ
រិទ្ធិសែនខំអត់ក្ដីសោកសៅ    ហើយនាំនាងទៅលើប្រាង្គប្រា
ព្រលប់ដល់ពេលសោយក្រយ៉ា    ទ្រង់បង្អកស្រានាងកង្រី ៗ

ឯពួកពលយក្សទាំងអស់គ្នា    រាជាបង្អុកគ្មានប្រណី
ស្រវឹងខ្លាំងណាស់ទន់ជើងដៃ    ឃ្លាតខ្លីទៅរកកន្ទែងដេក ៗ
ដល់ហើយប្រាសខ្លួនទន់រងៀក    ស្រមុកគ្រូកគ្រាក់ខ្សួរគុម្ពបេក
យប់យូរសុនខកំពង់ដេក    ស្មានតែខ្លាស្រែកប្រឹងលូលាន់ ៗ
រនាងកន្រ្ទឹកស្រវឹង    ចូលផ្ទុំសន្ទឹងដូចកំពាន់
រិទ្ធិសែនឃើញហើយប្រឹងរសាក់    បន្ទាន់ចូលយកកូនសោភ្លាម ៗ
បានហើយយាងទៅឯឃ្លាំងតូច    ព្រះវិទសំរួចមិនទំមទៀម
ចូលដល់ចាក់សោរបើកទ្វារភ្លាម    ទន្ទ្រាមដល់តុះតម្កល់ពាន ៗ
ទ្រង់យកដបថ្នាំទឹងដំបង    ពានដាក់ក្នុកផង យ៉ាងខ្លាហាន
ហើយវិលចូលក្នុងប្រាសាទស្ថាន    ក្បែរក្សាន្តលបៗខ្លាចនាងភ្ញាក់ ៗ
ដល់ហើយចាប់ស្រស់ព្រលឹង    ពេលទឹងបង់សូមលាវរលក្ខណ៍
យប់នេះរៀមខានបានរួមរ័ក្ស    ហើយទ្រង់បើបក្រដោយអាលៃ ៗ
ងៀកចេញទៅក្រៅចិត្តកន្រែក    ក្នុងទ្រូងស្មើបែកស្ដាយស្រីថ្លៃ
ទឹកថាបើអញទៅហើយនៃ    ចមរៃត្រៃក្រោកឡើងសំសោក្កា ៗ
ប៉ុន្តែពេលនេះបើមិនទៅ    មាតាលោកនូវសំទុក្ខា
ណ្ហើយចុះគួរគាត់ក្តីស្នេហា    ទៅជួយមាតាឲ្យរួចទុក្ខ ៗ
បើអញស្រឡាញ់នារីរត្ន័    ទឹងភជសម្បត្តិខ្លួនបានសុខ
ឲ្យអ្នកមានគុណនៅរងទុក្ខ    ឯងសុខតែឯងពុំគួរការ ៗ
ស្ដេចខឹកសព្វគ្រប់ចេញទៅក្រៅ    ចៅហ៊ឺនៅយកសេះ ហ៊ើយណា

ឡើងគង់លើខ្នងបរយាត្រា ក្សត្រាសំដៅទៅបុរី ។
លុះស្តេចទៅដល់កណ្តាលផ្លូវ មើលទៅឃើញព្រះមហាឥស្សី
ចុះពីខ្នងសេះទៅឃ្លាតខ្លី បង្គំឥស្សីយ៉ាងគោរព ។
ឥស្សីទ្រង់ញាណដឹងប្រាកដ ថាកុមារតែចេញតាំងយប់
ពោលនាងក្រធឹមិនហ៊ានឈប់ ព្រោះអង្គចមក័ព្វទឹកមាតា ។
ទ្រង់មានព្រះទ័យអាណិតណាស់ ហើយត្រាស់ថានែអង្គកុមារ
ចូរអ្នកចំស្រុកទៅសេមា ធ្វើការឲ្យបានសម្រេចឆាប់ ។
បើប្រពន្ធតាមមកទាន់ហើយ ត្រូវធ្វើប្រងើយហៅកុំស្តាប់
គោងស្រូតដំណើរឲ្យប្រញាប់ តែយូរម្តាយស្លាប់អាសាបង់ ។
ហើយដំបងពេជ្រនាងសន្ធមារ ពូកែអស្ចារ្យបើបង់ជួន
ទន្ទេប្ញស្សីនព្រៃកំផង ក្រវីដំបងហោះធ្លុងបាន ។
មួយទៀតបើប្រពន្ធនាំពល តាមមកបានយល់លំបាកប្រាណ
ទឹងគិបឲ្យផុតក្នុងស្មាន ប្រុងប្រាណបោះមែកឈើនេះទៅ ។
ទឹងទាំងផ្លូវនាងតាំងអស់គ្នា កុំឲ្យវេទនាទៅតាមផ្លូវ
ឥស្សីប្រាប់ហើយទ្រង់យាងទៅ ចូលក្នុងព្រៃជ្រៅតែឯកា ។
ឫទ្ធិសែនបើងស្ទុះបង្អង់ខាន ជាប់ផ្តើមនិទានពីជីតា
ភ្ញាក់ឡើងពីព្រឹកឆាកស្រក៉ រាវរកក្សត្រាពុំយល់ឡើយ ។
ស្ទុះចេញមកក្រៅហៅក៏លៀង ថានាងបានឃើញអង្គត្រាណាត្រើយ
ព្រះស្វាមីអញទៅណាហើយ គោងធ្វើយប្រាប់មកឲ្យយ៉ាងឆាប់ ។

គីលៀនត្កហើយស្ទុះក្រោកខ្ទី　　ចេញវៃមកខ្ចួលជាប្រញាប់
ថាមិនឃើញទេស្ងួមទ្រង់ជ្រាប　　យប់មិញស្ងាត់ជ្រាបគ្មានពុស្សី ៗ
នាងបានត្កពួកគីលៀនថា　　មិនឃើញក្សត្រាជាស្វាមី
នាងទឹកស្គាយណាស់ព្រោះប្ដី ៗ　　ហេតុអ្វីបានជាទៅមិនដឹង ៗ
ឯនាងកន្ទ្រីប្រាប់សេនា　　ឲ្យប្រមូលគ្នាមកពេលហ្នឹង
ពួកយក្សគ្រាន់តែឮដំណឹង　　រត់ត្រង់ដើងក្ដឹងមកជុំគ្នា ៗ
ហើយលើកទ័ពចេញជាប្រញាប់　　ដំណើរយ៉ាងឆាប់មិនរេរា
សន្ធឹកដូចក្បុះសង្គ្រា　　បព្វតាបាក់ខ្ទិចដោយវាជាន់ ៗ
ពលយក្សប្រឹងរត់គ្មានបង្អង់　　សំដៅយ៉ាងត្រង់ទ័ពមួយពាន់
កាត់កាលចូលព្រៃគ្មានធុញទ្រាន់　　រត់ជាន់បាក់ខ្ទិចអស់ដើមឈើ ៗ
ប្រឹងប្រូតដំណើរពេញ១ថ្ងៃ　　ទើបទាន់ក្សត្រថ្ងៃស្រែកបណ្ដើរ
ថាឱម្ចាស់ថ្លៃរូបប្រសើរ　　ម្ដេចតើរត់មកចោលប្អូនស្រី ៗ
ព្រះបាទរិទ្ធិសែនទតឃើញច្បាស់　　ភ័យណាស់តាប់កាន់ដំបងខ្ទី
ក្រវីកាលណាសេះចក្រី　　ហោះបើឡើងលើអាកាសា ៗ
ហើយទ្រង់បោះមែកឈើដែលឥ　　ស្បៀប្រទានខ្ទិចក្រា
ព្រះធរណីស្រុតធំអស្ចារ្យ　　មានទាំងដល់សាហូរបុះមក ៗ
ទៅជាស្ទឹងមួយធំពេកក្រៃ　　ស្រីថ្ងៃធ្ងន់មិនរួចនាងសោក
សម្រែននៃស្រែកហៅឲ្យបុះមក　　ស្រស់ឆោមពន្ធុកវែងខ្លោចផ្សា ៗ
រិទ្ធិសែនញាក់សេះទាក់រលមក　　ថាឱពន្ធុកគូដីរ៉ា

សូមនាងវិលទៅរាជសោមា បងលាធីតាទៅសិនហើយ ៗ
នាងថាឱ! ស្វាមីសម្លាញ់ ពុំគួរឃ្លាតចេញពីប្អូនឡើយ
សមប្អូនសង្រេងពុំមានស្បើយ ម្ចាស់អើយឲ្យប្អូនសូមទៅផង ៗ
នាងអង្វរហើយយំក្ដួងៗ កងទ្រូងបំបែងពេកកន្លង
រិទ្ធីសែនឃើញច្នោះកក្រសៅហ្មង ថាឱមាសបងកុំសោកឡើយ ៗ
បងទៅមិនយូរប៉ុន្មានទេ រៀមនឹងវិលរមកកៀកកើយ
ពេលនេះបងសូមលាទៅហើយ គ្រាណាត្រើយកុំតាមបងទៅថ្វី ៗ
នាងថាបើមិនឲ្យខ្ញុំទៅ ប្អូនដើរតាមផ្លូវទាល់តែក្ស័យ
ខ្ញុំមិនវិលទេរាជបុរី ខានអស់សេរីយ សុខចិត្តស្លាប់ ៗ
រិទ្ធិសែនអាណិតនាងខ្លាំងណាស់ ហើយត្រាស់ថាឱស្រស់បំណាច់
នាងគិតដូច្នោះពេញពុំគាប់ ត្រូវនាំពួកទ័ពទៅបុរី ៗ
ទ្រង់នឹកអាណិតបងបុះទៅ តែសេះហោះស្ទុះលឿនប្រៀបប្រែ
ពេលនោះរីឯនាងកន្និ ស្រែកហៅក្សត្រថ្លៃយំក្ដួងៗ ៗ
នាងតាមមើលទាល់ផុតបុងភ្នែក ទ្រូងប៉ុកស្ទើរបែករឹងបំបែង
ហើយប្រាប់សេនាថាអ្នកឯង ប្រឹងប្រែងរក្សារាជបុរី ៗ
យើងមិនបានវិលទៅវិញទេ ត្រូវអ្នករិះរេជាប្រក្រតី
មើលថែរក្សាជនប្រុសស្រី ឃ្លាតខ្ចីដូចអ្នករក្សាកូន ៗ
រាជការធំតូចត្រូវចងបាច់ មិនត្រូវបែរគេចចិត្តដោយខ្លួន
តែបែកសាមគ្គីមិនបណ្ដូន ដូចទូកទាញក្បួនឡើងប្រះសទឹក ៗ

នាងចុកខ្លាំងណាស់ស្ទះម្តងៗ　　ដូចគេសំពងដោយសារដេក
ដល់អគ្គិស្វាមីស្មារតីភ្ញឹក　　ក្រោកខ្លួនស្ទុះលើធរណី ។
នាងក្រោកប្រាសខ្លួនទៅទឹងដី　　បែកព្រះសិរសីក្ស័យជីវី
ទៅជិតគល់ឈើមាត់ដលធី　　នារីក្សីណក្ស័យអសារបង់ ។
ថ្ងៃនពិរិទ្ធីសែនដែលហោះទៅ　　សំដៅចូលក្នុងបុរីរង្គ
ដល់ហើយចូលក្លាមមិនបង្អង់　　ដម្រង់ទៅរកព្រះមាតា ។
នាងទៅឃើញកូនចូលមកដល់　　ប៉ាត់ខ្វល់ហើយសួរទៅកូនថា
កូនឯងទៅបាត់ម្តាយខ្វាចផ្សារ　　តើកូនទៅណាប្រាប់ម្តាយផង ។
រិទ្ធីសែនដំរាបតាមសេចក្តី　　ដែលបានស្រដីមកហើយហោង
ម្តាយឮត្រេកអរពេកកន្ទង　　ទាំងម្តាយធំផងសឹងរីកកាយ ។
រិទ្ធីសែនយកគ្រាប់ក្តុកដាក់ឲ្យ　　ដាក់ថ្នាំបណ្តាយក្តីត្រសាយ
ដូចកាលដើមវិញ្ញៈពញ្ញសប្បាយ　　បាត់តើតក្រហាយបាត់ឈឺចាប់ ។
រួចហើយទ្រង់នាំមាតាទៅ　　បង្គំចមទៅជាប្រញាប់
ទូលថាបិតាសូមទ្រង់ជ្រាប　　ដោយភាពខ្លួនខ្ញុំជាពជបុត្រ ។
ចំណែកឯនាងសន្ធមា　　គឺវាយក្សាពិតប្រាកដ
ហើយទ្រង់ដំបងចង្អុលថ្វាត់　　វរវិត្តប្រែជាយក្សិណី ។
ស្តេចទ្រង់ទឹកធ្ងល់ក្នុងចិន្តា　　តែគ្មានសន្ធនាតបថាអ្វី
លុះឃើញនាងយក្សខ្វាយខ្វនខ្វី　　ស្មើបាត់ស្មារតីកែម្នាក់ឯង ។
រិទ្ធីសែនវាយយក្សទឹងដំបង　　សំពងយ៉ាងខ្លាំងឥតមានក្រែង

ចំបន្ទូលក្បាលដួលប្រែខែង ឈាមបាញ់ដូចផ្សែងហូរជោកដី ៗ
ដំបងនោះមានឫទ្ធិអស្ចារ្យ ត្រូវចំសិរសាយក្សិណី
ដួលប្រុសប្រកាច់ហាក់ដូចត្រី ក្សត្រីដាច់ខ្យល់មួយរំពេច ៗ
ទើបស្តេចសួរព្រះកុមារថា ឯងកូនអ្នកណាហើយហេតុម្តេច



បានជាដឹងការសព្វសាព្រើប ទប្រុះសួតសាប់ប្រាប់មកចូរ ៗ
រិទ្ធិសែនជាទូលព្រះបង្គំ ជាខ្ញុំពជបុត្រនៃនាងពៅ
ហើយទូលពីរឿងយក្សប្រែទៅ ដោមខ្លៅបានដឹងសព្វសេចក្តី ៗ
ទើបលួចរត់មកតែឯកា យកទាំងនេត្រាមាតាខ្ញី
មកបន្ទូលវិញដូចប្រក្រតី ក្សត្រថ្លៃថ្លាហើយស្ទើរខ្លោចចិត្ត ៗ

ហើយលោមម្ហូសីថាព្រលឹង ចូរកែវកុំខឹងណាវរមិត្រ
បងគ្មានដឹងទេរឿងនោះពិត បងគិតថាកាប់បំបរមង់ ៗ
ក្សត្រាអាណិតបុត្រពេកក្រៃ ថាឱថ្ងើមថ្ងៃគ្រានេះមួង
បិតាឲ្យបុត្រគ្រងរាជស្នង តវង្សរៀងទៅស្រេចលើបារ ៗ
រីឪសែនពុំព្រមទទួលរាជ ព្រោះទ្រង់ទឹងខ្លាចមានទោសា
តែសោយរាជហើយចិត្តហានខ្លា ពុំមានរអាទឹងបាបកម្ម ៗ
ហេតុនេះសូមលាព្រះបិតា បួសកន្សបត្តាធ្វើបន្ទ្រឹ
ការនារក្សាទាំងសីលប្រាំ កុំគិតបងចាំសីលប្រាំបី ៗ
ស្តេចទ្រង់ទឹកព្រួយព្រះបិន្តា ស្មានថារាជបុត្រអន់ព្រះទៃ
ទើបទ្រង់អង្វរថាបុត្រថ្លៃ កុំទៅធ្វើអ្វីប្រុសពុំការ ៗ
ទុក្ខទោសដែលយករាជធ្វើនោះ បំពោះវរបីតតដឹងការណ៍
ហេតុនេះសូមបុត្រកុំក្រោធា នៅគ្រងសេមាចំនួសបូរ ៗ
រីឪសែនបង្គំថាសូមទោស សូមទានទ្រង់ប្រោសគ្រានេះកូវ
មេត្តាបើកឲ្យបុត្រចេញទៅ បុត្រនឹងទ្រាំនៅពុំបានឡើយ ៗ
ក្សត្រាល្ហួងលោមបុត្រសព្វគ្រប់ ព្រះទៃធុញថប់ពុំមានស្បើយ
ដល្យូនេត្រហូរជោកអង្គត្រាណត្រើយ ទ្រង់ធ្លើយថាឱបុត្រសម្លាញ់ ៗ
បើបារទៅហើយឲ្យបានសុខ កុំបីមានទុក្ខទ្រូងក្តុនក្តាញ់
បំណែកបិតាតែងទុក្ខមិញ ពោះពេញទៅដោយក្ដីអាល័យ ៗ
រីឯនាងទាំងពីជន្ទប់ ឱទព្រះកក្រផ្ទប់ព្រួយពេកក្រៃ

អង្គរជាទីបុត្រថ្មីថ្ងៃ　អ្នកទៅនៅព្រៃពាលមាតា ៗ
សព្វថ្ងៃម្ដាយមានតែបារម្ភ　ឥតព្រួយទីពឹងស្មើដីកា
ឥឡូវបើកូនចាកសេមា　សុំម្ដាយខ្មោចផ្សាព្រួយចំបែង ៗ
នាងអង្គរបុត្រត្នស្នេហា　ដោជល់នគ្រាសោកសង្រែង
ព្រះទេឈឺឈួលអួលកន្ទេង　ចំបែងកងចិត្តឥតគណនា ៗ
រិទ្ធិសែនអង្គរព្រះមាតា　តាំងព្រះបីតាពីរអង្គារ
សូមទ្រង់កុំព្រួយព្រះទ័យា　ផនាខ្លួនកូនពុំមែនក្ស័យ ៗ
គឺកូនគ្រាន់តែចេញទៅបួស　សូមមាតាប្រោះពេលនេះនៃ
កុំឲ្យកូនតឹងទ្រូងពេកក្រៃ　បើពុំប្រណីកូនក្ស័យប្រាណ ៗ
នាងពីជន្ទប់ពុជ្ជទោះ　ប្រាប់ថាទៅចុះណាយើមាន
តែកងព្រះទៃវង់វិមាន　កល្យាណកាត់ចិត្តជាប្រុសថ្លៃ ៗ
បើបាទៅបួសនៅកងព្រៃ　ពេលណាខ្វះអ្វីប៉ូវកែខែ
វិលមករកម្ដាយណាប្រុសថ្លៃ　ម្ដាយនឹងឃ្លាតខ្លីរកឲ្យអ្នក ៗ
រិទ្ធិសែនពុម្ដាយព្រមឲ្យទៅ　ត្រេកអរពេកក្រូវបែព្រះភក្ត្រ
ក្រាបថ្វាយបង្គំព្រះទ្រង់លក្ខ　ចេញចាកដើរទៅសំដៅព្រៃ ៗ
ទៅបួសហើយសំណាក់កម្មដ្ឋាន　កងព្រៃស្ងាសានឥតព្រួយអ្វី
រាល់ពេលវេលាតែងឃ្លាតខ្លី　ដើម្បីឲ្យបានរួចចាកទុក្ខ ៗ
ព្រះបាទរិទ្ធិសែនបួសជាសង្ឃ　នៅកងព្រឹកព្រៃសិងបានសុខ
សត្វព្រៃក៏គ្មានហ៊ានទើសមុខ　ទ្រង់គង់ជាសុខគ៏រៀងទៅ ៗ

នាងពីដន្ទប់នឹងក្សត្រា　　នូវក្នុងសេមានោះឯងក្បូរ
បានសេចក្ដីសុខគ្មានហ្មង់សៅ　　ព្រះចៅលើកនាងធ្វើជាធំ ៗ
អស់ពួកទាសីស្រីបរើ　　នៅថែរក្សាមួលកុះកុំ
នាងពីដន្ទប់ក៏សុខំ　　ព្រោះទ្រង់ទីយាំព្រោសប្រណី ៗ
ហេតុនេះទាសីសឹងកោតខ្លាច　　មិនអាចធ្វើឲ្យឃ្លើសព្រះទៃ
ព្រោះខ្លាចអំណាចព្រះចក្រី　　ក្សត្រីបានសុខតរៀងទៅ ៗ
រឿងនេះសន្និម៉ត់ចប់ប៉ុណ្ណោះ　　ខ្ញុំសូរបេះពាក្យជ្រាលជ្រៅ
រៀនតែងដំបូងទោះខុះត្រូវ　　សូមមិត្រញាតិចៅកុំប្រកាន់ ៗ
ព្រោះខ្ញុំមែនជាបណ្ឌិត　　ឃើញរឿងនេះពិតយ៉ាងបំណាន
តែពាក្យនោះពយខ្ញុំរំខាន　　ចង់បានជាកាព្យទើបពេញចិត្ត ៗ
ហេតុនេះខ្ញុំលើកជាកាព្យឃ្លោង　　ក្នុងគ្រាដំបូងម្ដងនេះពិត
បើមានខុះឆ្គងពីគំនិត　　សូមលោកបណ្ឌិតជួយកែផង

ចប់

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម-គី គឺ:

| | | |
|---|---|---|
| ច្បាប់បរទ្យាន . . . . | ១សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . | ” | ៨៛០០ |
| តេជាដំឌិន ទី ១ ដល់ទី ៧ ចប់ . . | ” | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . . . | ” | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . | ” | ៦៛០០ |
| រឿងធន្ធមឿង ទី ១ ទី ២ ចប់ . . | ” | ៨៛០០ |
| រឿងធ្មេញជ័យ . . . . | ” | ១២៛០០ |
| រឿងអាឡាដាំងមនុស្សម្នាត់ទិព្វចង្កៀងទិព្វ | ” | ១៨៛០០ |
| រឿងព្រះសធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ” | ៩៛០០ |
| រឿងស្វូផាត . . . . | ” | ១០៛០០ |
| ពិម្ពាពិលាប . . . . | ” | ១០៛០០ |
| នានាធម្មសំវេគ . . . . | ” | ៨៛០០ |
| ល្បើកសត្វអក . . . . | ” | ៤៛០០ |
| កុមារផ្ដាន . . . . . | ” | ១០៛០០ |
| រឿងតាវឯក ទី ១ ទី ២ ទី ៣ ទី ៤ . | ” | ៤៛០០ |
| សេកសារិកា . . . . | ” | ៧៛០០ |
| រឿងរតនាវង្ស ទី ៦ ទី ៧ ទី ៨ . . | ” | ៥៛០០ |
| សុន្ទរកថា . . . . . | ” | ៥៛០០ |
| ទេវតាភាសិត . . . . | ” | ៥៛០០ |

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម-គី គី:

| | | |
|---|---|---|
| បកិណ្ណកបរិត | ១ សៀវភៅថ្លៃ | ១២៛០០ |
| វេយ្យាករណ៍បា ទី ១ | " | ១៨៛០០ |
| " " ទី ២ | " | ១៧៛០០ |
| វេយ្យាករណ៍ខ្មែរ | " | ១៣៛០០ |
| លេខទៀរ៍ | " | ១៥៛០០ |
| ធម្មសង្គហៈ ភាគ ១ ភាគ ២ | " | ១៥៛០០ |
| បញ្ញានិទ្ទេស | " | ២៥៛០០ |
| ប្រស្នាគិហិបដិបត្តិ | " | ១៨៛០០ |
| វិធីប្រែបាលី | , | ២៥៛០០ |
| ប្រស្នាអភិធម្ម | " | ២៥៛០០ |
| ប្រស្នាត្រៃគុណ | " | ៦៥៛០០ |
| សាមណេរវិន័យបញ្ហា | " | ២០៛០០ |

## សៀវភៅកំពុងបោះពុម្ពទៅ

រឿងដំបងក្រញូង - ភ្នាក្រែក - បក្សីចាំក្រុង

| | |
|---|---|
| រឿងនាងពីដណ្ដប់ | រឿងចម្ប៉ាថោងចិញ្ចឹមក្រពើ |
| រឿងព្រះថោង នាងនាគ | រឿងព្រះបាទអជាតសត្រូវ |
| រឿងព្រះបទុមគោរព | រឿងជ័យសូរវង្ស |
| រឿងនិទានទេវទត្ត | រឿងព្រះសុវណ្ណវង្ស |

នឹងសៀវភៅ បារាំង-ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេក្រង

ជិតរោងកុនព្រហ្មបាយយ័នផ្ទាល់ ភ្នំពេញ

រក្សាសិទ្ធិ


រោងពុម្ពអាស្យ៉ាទិជ
ភ្នំពេញ